ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

មហាវិទ្យាល័យអក្សរសាស្ត្រ

ឯកទេស: បរិស្ថានវិទ្យា

មុខវិជ្ជា: នីតិបរិស្ថាន

# កិច្ចការស្រាវជ្រាវ: អំពីវត្តអារាម និងបរិស្ថាន

បង្រៀនដោយលោកគ្រូសាស្ត្រាចារ្យ: កែវ ហេង

ស្រាវជ្រាវដោយ:

-សមណ:និស្សិត សាន វិសាល

-សមណ: និស្សិត សាយ តាក់

-សមណ:និស្សិត ទុន ធារិទ្ធ

និស្សិត ឡឿក រតនា

ឆ្នាំទី ២ ឆមាសទី ១

ឆ្នាំសិក្សា

ព.ស ២៥៦១ គ.ស ២០១៧

# មាតិកា

I សេចក្ដីផ្ដើម ........................................................................................................ ១
ប្រវត្តិពុទ្ធសាសនាចូលមកក្នុងប្រទេសកម្ពុជា ........................................................................ ២
សារប្រយោជន៍នៃវត្តអារាម ........................................................................................ ៣
ឥទ្ធិពលនៃវត្តអារាមទៅលើសង្គមខ្មែរ ........................................................................... ៤
វត្តអារាម និងបរិស្ថាន ............................................................................................... ៧
ព្រះសង្ឃនិងការតិវឌ្ឍន៍សង្គមបរិស្ថាន ......................................................................... ១២
១.១ បរិស្ថានជាអ្វី? ................................................................................................. ១៥
II សេចក្ដីសន្និដ្ឋាន .................................................................................................... ១៩
ឯកសារយោង ............................................................................................................... ២១

# សេចក្ដីផ្ដើម

នៅលើពិភពលោក ប្រទេសអភិវឌ្ឍន៍ និង ប្រទេសកំពុងអភិវឌ្ឍន៍ កំពុងចាប់អារម្មណ៍ទៅលើបរិស្ថាន ពិសេសការព្រួយបារម្ភចម្បងមួយដែលប្រជាជននិងរដ្ឋាភិបាលនានាកំពុងតែប្រឈមមុខនោះ គឺមានកំណើនប្រជាពលរដ្ឋ ការដុតឥន្ធន ផូស៊ីល ការបំផ្លាញព្រៃឈើ ការបំពុលទឹក ការបំពុលខ្យល់ ការបំពុលដី ការចាក់សំណល់ចោល ភាពក្រីក្រនិងការបាត់បង់ប្រភេទសត្វនិងរុក្ខជាតិនានា។

បរិស្ថានមានន័យថា មជ្ឈដ្ឋានជុំវិញខ្លួន បើនិយាយឲ្យងាយយល់ មានន័យថាខ្លួនយើងគ្រប់រូបដែលមានសាពាង្គកាយជាមនុស្សរួមជាមួយពិភពមនុស្ស ពិភពធម្មជាតិ និងពិភពវប្បធម៌ដែលនៅជុំវិញយើង។ វត្តអារាមដើរទូនាទីសំខាន់ ហើយមានឥទ្ធិពល និងមានគុណប្រយោជន៏ ផ្ទាល់ក្នុងការលើកទឹកចិត្តឲ្យមានការសង្គ្រោះរវាងមនុស្សសត្វនិងធម្មជាតិរួមទាំងការធ្វើឲ្យបរិស្ថានកាន់តែមានភាស្អាតនិងល្អ។

បច្ចុប្បន្ននេះ មនុស្សកើតកាន់តែច្រើន ពិភពលោកក៏ក្លាយទៅជាទីចង្អៀតដោយឥទ្ធិពលនៃការរីកចម្រើនខាងវិទ្យាសាស្ត្រ។ ពិភពថ្មីរបស់យើងនេះ ពោពេញដោយការលោភលន់ ការស្អប់ខ្ពើមគ្នា ការច្រណែនឈ្នានីស និងការបង្ករសង្គ្រាមកាប់សម្លាប់គ្នា។ ដោយសារតែពិភពលោកនេះចេះតែតូចចង្អៀត ហើយធ្វើអោយមនុស្សនៅលើផែនដីនេះមានការប៉ះទង្គិចគ្នាមិនចេះចប់។ ប៉ុន្តែមនុស្សនិងមនុស្ស មនុស្សនិងធម្មជាតិមានការទាក់ទងគ្នាទៅវិញទៅមក មិនអាចកាត់ផ្ដាច់ពីគ្នាបាន។ ពិភពលោកនេះជាពិភពដែលពុំមានភាពជាអមតៈទេ មនុស្សទាំងអស់ដើរលើផ្លូវតែមួយ គឺដើរទៅរកការស្លាប់ឥតមាននរណាដើរចេញពីផ្លូវនេះបានឡើយ។ ដូច្នេះមានតែការជួយសង្គ្រោះគ្នា ការអាណិតអាសូរគ្នា ការចេះអោយតម្លៃគ្នាទៅវិញទៅមក និងការរំដោះខ្លួនអោយចេញពីពិភពអាត្មានិយមដ៏តូចចង្អៀតនេះ ត្រឡប់មករស់នៅក្នុងពិភពរួមនៃព្រហ្មវិហារធម៌របស់ព្រះពុទ្ធវិញ ទើបយើងអាចរកសេចក្ដីសុខបានខ្លះ ក្នុងជីវិតដ៏ខ្លីរបស់ខ្លួននេះ។

# ប្រវត្តិពុទ្ធសាសនាចូលមកក្នុងប្រទេសកម្ពុជា

ពុទ្ធសាសនា បានកើតមានឡើងនៅក្នុងប្រទេសឥណ្ឌា មុនគ្រិស្តសករាជ ៥៤៤ ឆ្នាំ។ យោងតាមគម្ពីរសាមន្តបាសាទិកា អដ្ឋកថា វិន័យបិដក និងសិលាចារិខ្លះព្រមទាំងប្រវត្តិសាស្ត្រផ្សេងៗទៀត ពុទ្ធសាសនាត្រូវបានព្រះសោណត្ថេរ និងព្រះឧត្តរ នាំយកមកផ្សាយក្នុងដែនដី សុវណ្ណភូមិ (រួមប្រទេសកម្ពុជាយើងផងដែរ) តាមព្រះថេរបញ្ជារបស់ព្រះមោគល្លីបុត្តតិស្សត្ថេរ និងក្រោមព្រះរាជូបត្ថម្ភរបស់ព្រះបាទអសោក នៅក្នុងពុទ្ធសតវត្សទី ៣។

តាំងពីពេលនោះមក ពុទ្ធសាសនាបានប្រតិស្ឋាន នៅក្នុងប្រទេសកម្ពុជា អស់ពេលជាយូរមកហើយ មានទាំងព្រះសង្ឃនិងវត្តអារាមពុទ្ធសាសនា ដែលបានធ្វើឲ្យមានការជ្រួតជ្រាបចូលជ្រៅក្នុងចិត្ត ក្នុងសតិអារម្មណ៍របស់ប្រជាជនខ្មែរ។ ដូចជានៅក្នុងបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ (ដែនដីសុវណ្ណភូមិពីបុរាណកាល) ខ្លះទៀតដែរ ពុទ្ធសាសនានៅប្រទេសកម្ពុជា មិនមែនគ្រាន់តែជាប្រភព សម្រាប់ការប្រតិបត្តិខាងសាសនា នឹងខាងសីលធម៌ ប៉ុណ្ណោះទេ ប៉ុន្តែ នៅបានជាប្រភពដ៏មានឥទ្ធិពលទៅលើជីវភាពសង្គម និងវប្បធម៌ បរិស្ថានទៀតផង។

# សារប្រយោជន៏នៃវត្តអារាម

វត្តអារាម ជាមជ្ឈមណ្ឌលពុទ្ធសាសនា ជាទីសក្ការបូជា ដែល ពុទ្ធបរិស័ទមកជួបជុំ មូលមុំគ្នា ទទួលយក និង ចែករំលែក នូវសេចក្ដីស្ងប់ក្នុងចិត្ត សេចក្ដីរីករាយ និង សេចក្ដីស្រឡាញ់រាប់អាន ចំពោះគ្នាទៅវិញទៅមក, ចែករំលែកនូវបញ្ញា និង ចំណេះចេះដឹងផ្សេងៗ ជាពិសេស ចំណេះដែលទាក់ទង នឹងពុទ្ធសាសនា, ចែករំលែកនូវសប្បុរសទាន និង ទទួលនូវមេត្តាធម៌ គឺអំពើល្អទាំងឡាយ ជូនដល់ជីវិតមនុស្សទូទៅ តាមបុណ្យសទ្ធាតាមលទ្ធភាពនិងសមត្ថភាពដែលពុទ្ធបរិស័ទអាចធ្វើទៅបាន។

វត្តអារាមមានសារប្រយោជន៍ជាច្រើនទៅដល់សង្គមខ្មែរ វត្តអារាមមិនមែនជាកន្លែងសម្រាប់តែប្រារព្ធពិធីតាមបែបព្រះពុទ្ធសាសនា និងជាទីកន្លែងសម្រាប់ព្រះសង្ឃគង់នៅតែប៉ុណ្ណោះទេ ជាងនេះទៅទៀត វត្តអារាមជាកន្លែងសម្រាប់បង្ហាញនូវអត្តសញ្ញាណនិងវប្បធម៌ខ្មែរ។វត្តក៏ជាជម្រកសម្រាប់សិស្ស និស្សិតជាច្រើនមកពីជនបទចុងកាត់មាត់ញក ដែលមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរកលុយដើម្បីជួលផ្ទះ បានចូលទៅសុំស្នាក់អាស្រ័យ ដើម្បីបន្តការសិក្សារបស់ពួកគេ។តាំងពីដើមរហូតមក វត្តអារាមមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្ដុះបណ្ដាលយុវជនខ្មែរឲ្យក្លាយជាធនធានមនុស្សដ៏សំខាន់សម្រាប់សង្គម។ អ្នកប្រាជ្ញអក្សរសាស្ត្រ កវីនិពន្ធនៅសម័យមុនៗ ភាគច្រើនសុទ្ធតែធ្លាប់បានបួសរៀន និងស្នាក់នៅនឹងវត្តអារាម។ប្រហាក់ប្រហែលគ្នានេះដែរ ពេលបច្ចុប្បន្នវត្តអារាមនៅតែមានតួនាទីយ៉ាងសំខាន់សំរាប់យុវជនក្រីក្ររាប់រយនាក់ ដែលមកពីតំបន់ដាច់ស្រយាលស្នាក់នៅរៀនសូត្របន្ត នាទីក្រុងភ្នំពេញ។ សិស្ស និងនិស្សិតជាច្រើនដែលទទួលអាហារូបករណ៏រដ្ឋ ហើយពួកគេមកបន្តការសិក្សានាទីក្រុងភ្នំពេញ ភាគច្រើនមិនមានលទ្ធភាពគ្រប់គ្រាន់រកលុយបង់ថ្លៃផ្ទះ

នោះឡើយ ដោយសារឪពុកម្ដាយក្រីក្រ។ ដូច្នេះពួកគេទាំងនោះភាគច្រើនមានតែមកសុំស្នាក់អាស្រ័យនឹងវត្តអារាមជាមួយព្រះសង្ឃ។

វត្តអារាមជាទីជម្រកសំរាប់ការសិក្សារៀនសូត្រ របស់កុលបុត្រកុលធីតាខ្មែរ អ្នកក្រីក្រ និង អ្នកស្រែចំការទូទៅ នៅប្រទេសកម្ពុជា។ កាលសម័យមុន ធនធានមនុស្សមួយចំនួនធំ សុទ្ធតែចេញមកពីវត្តអារាម ក្នុងនាមជាអ្នកបួសរៀន ឬ ជាសិស្សក្មេងវត្ត ហើយភាគមួយចំនួនធំគឺ រៀនអំពីវប្បធម៌-អរិយធម៌ខ្មែរ និង ក្រមសីលធម៌គ្រប់បែបយ៉ាង។

# ឥទ្ធិពលនៃវត្តអារាមទៅលើសង្គមខ្មែរ

វត្តអារាម សំនៅលើទីកន្លែងសម្រាប់ព្រះសង្ឃគង់នៅប្រតិបត្តិធម៌វិន័យ និងជាកន្លែងសម្រាប់ជនទូទៅគោរពបូជា និងធ្វើបុណ្យផ្សេងៗតាមបែបព្រះពុទ្ធសាសនា និងជាគ្រឹះទ្រទ្រង់ព្រះពុទ្ធសាសនា ប្រពៃណី ទំនៀនទម្លាប់ វប្បធម៌ អរិយធម៌ ជាតិឲ្យបានគង់វង្ស និងជាមន្ទីរពេទ្យព្យាសម្រាប់ព្យាបាលចិត្តគំនិត ឬអារម្មណ៍សៅហ្មង ទាំងពួងឲ្យ បាននៅស្ងប់ស្ងៀម និងជាកន្លែងដែលជាទីរីករាយមនោរម្យផងដែរ។

ហេតុដូច្នេះហើយ វត្តអារាមរបស់ព្រះពុទ្ធសាសនា នៅកម្ពុជា ត្រូវបានគេចាត់ទុកជា មជ្ឈមណ្ឌលនៃអត្តិភាពរបស់ប្រជាជន ទាំងជាផ្នែកមួយនៃទេសភាពរបស់ប្រទេស ក្នុងន័យដែលវត្តអារាមទាំងឡាយ បានជាទីរក្សាការពាររុក្ខជាតិជាច្រើនប្រភេទ ដែលផ្ដល់ផលប្រយោជន៍ដល់មនុស្សជាច្រើនដូចជាៈ ជាអាហារ គ្រឿងសង្ហារិម ថ្នាំព្យាបាលរោគ សម្ភារៈប្រើប្រាស់ផ្សេងៗទៀត...។ល។ និងផ្ដល់ជម្រកដល់សត្វ (សត្វស្លាប សត្វចតុប្បាទតូចតាច)។ ក្រៅពីនេះ ការរក្សារុក្ខជាតិ ន៏ងឆ្កឹងឆ្ពោលអោយនៅក្នុងវត្ត អាចធ្វើឲ្យខ្យល់អាកាសស្អាតល្អ និងរក្សាបាននូវទឹក។ ខ្យល់

អាកាសស្អាតល្អ និងមានទឹកសម្បូរ មានសារប្រយោជន៍ខ្លាំងណាស់ដល់ជីវិតរបស់មនុស្ស។

ម្យ៉ាងវិញទៀត ជាទម្លាប់ជាប់តាំងពីបុរាណកាលមក ដែលវត្តអារាមភាគច្រើនតែងតែបានជីកស្រះទឹកមួយ ឬពីរ ដើម្បីរក្សាទឹកទុកប្រើប្រាស់ ជួនកាលមានរំលិច ត្រពាំង ឬស្មូរធម្មជាតិនៅក្នុងទីវត្តអារាម ដែលត្រូវបានថែទាំឲ្យមានទឹកដក់ជាអចិន្ត្រៃយ៍ សម្រាប់សេចក្តីត្រូវការរបស់វត្ត ក៏ដូចជាសម្រាប់សេចក្តីត្រូវការរបស់អ្នកភូមិជុំវិញវត្តផងដែរ។ នៅក្នុងស្រះ រំលិច ត្រពាំង ស្មូរ ទាំងនោះតែងមានវារីជាតិ ដូចជាឈូក ព្រលិត រំចង់...ស្មុះរហង់ និងមានមច្ឆជាតិជាច្រើនប្រភេទ រស់នៅជួយបង្កអោយទីវត្តអារាម មានបរិយាកាសមនោរម្យ ស្ងប់ចិត្ត ស្ងប់អារម្មណ៏។

ដោយមានជំនឿមុតមាំទៅលើពុទ្ធសាសនា ដោយសារព្រះពុទ្ធសាសនាបានពន្យល់ ណែនាំគេអោយឃើញនូវមធ្យោបាយដោះស្រាយរាល់បញ្ហាដែលចោទ ឡើងក្នុងជីវិតប្រកបដោយហេតុផល យើងអាចមើលឃើញថា កន្លែងណាមានប្រជាជនច្រើនកុះករ កន្លែងនោះតែងតែមានវត្តអារាម។

ចំពោះប្រជាជនខ្មែរ វត្តអារាមជាទីពឹងពំនាក់ ជាបង្អែកខាងផ្លូវចិត្ត ជាកន្លែងសំរាប់ផ្តល់នូវបុណ្យកុសលគ្រប់បែបយ៉ាង។

គេប្រារព្ធធ្វើបុណ្យផ្សេងៗ ដែលជាប្រពៃណីព្រះពុទ្ធសាសនាក្តី ជាទំនៀមទម្លាប់របស់ប្រជាពលរដ្ឋក្តី នៅក្នុងវត្តអារាម។ វត្តក៏ជាទីពំនាក់អាស្រ័យរបស់អ្នកដែលគ្មានទីពឹងដូចជា កុមារកំព្រា ចាស់ជរា ជាទីស្នាក់អាស្រ័យរបស់សិស្សានុសិស្ស ជាកូនចៅប្រជារាស្ត្រក្រីក្រ។ អ្នកដឹកនាំប្រទេសមួយចំនួន សុទ្ធតែបានស្នាក់នៅបន្តការសិក្សានៅទីវត្ត។

ប្រជាពលរដ្ឋយើងមួយចំនួន មានជំនឿលើវត្តអារាមថាជាមន្ទីរពេទ្យសំរាប់ព្យាបាលជំងឺខាងផ្លូវចិត្ត និងជំងឺផ្សេងៗទៀតផង។

វត្តជាឃ្លាំងចំណេះដឹង ជាបណ្ណាល័យ ជាសារមន្ទីរនៃវប្បធម៌ អក្សរសាស្ត្រជាតិនៅគ្រប់សម័យកាល ជាកន្លែងសិក្សាវិជ្ជាផ្សេងៗ ដូចជាៈ អក្សរសាស្ត្រ លេខនព្វន្ត និងចំណេះដឹងផ្សេងៗចាំបាច់ សំរាប់ប្រើក្នុងជីវិត។

វត្តក៏ជាតុលាការរបស់ប្រជារាស្ត្រក្នុងភូមិ-ឃុំ ពេលណាប្រជាជនជើងវត្តមានទំនាស់ ទាស់ទែងខ្វែងគំនិតគ្នាក្នុងគ្រួសារក្តី រវាងញាតិសន្តានក្តី ក៏ព្រះសង្ឃរួមចំណែកជួយដោះស្រាយ ដោយបិណ្ឌបាត សេចក្តីលោភក្រេវក្រោធ កំហឹង ហឹង្សានោះចេញ។ តួនាទីរបស់វត្តដែលលើកឡើងខាងលើនេះ បង្ហាញឲ្យឃើញថា ពុទ្ធសាសនាមានសារសំខាន់ណាស់ សំរាប់ជួយដល់ប្រជាជនខ្មែរយើង ដោយឃើញឥទ្ធិពលវត្តអារាមជួយនៅក្នុងសង្គមខ្មែរជាច្រើន ដូច្នេះត្រូវបានប្រជាជនកម្ពុជា ជឿជាក់ហើយប្រតិបត្តិតាម ទុកដូចជាមាគ៌ាអនុវត្តជាក់ស្តែង សម្រាប់ជីវិត និងការជួយអភិវឌ្ឍសង្គមសម្រាប់ការរស់នៅរៀងរាល់ថ្ងៃរបស់ពួកគេ។

# វត្តអារាម និងបរិស្ថាន

វត្តអារាមមានន័យថា ជាទីកន្លែងដែលគួរបូជា ជាទីសការៈបូជា ឯ បរិស្ថានវិញមានន័យថាអ្វីៗនៅជុំវិញខ្លួនយើងទាំងមានជីវិតក្តីទាំងគ្មានជីវិតក្តីហៅថា វត្តអារាមបរិស្ថាន។ វត្តអារាមដើរតួនាទីសំខាន់ ហើយមានឥទ្ធិពល និងមានគុណប្រយោជន៍ផ្ទាល់ក្នុងការលើកទឹកចិត្ត ឲ្យមានការសង្គ្រោះរវាងមនុស្សសត្វ និងធម្មជាតិ រួមទាំងការធ្វើឲ្យបរិស្ថានកាន់តែមានភាពស្អាត និងល្អ ប្រសើរឡើងថែមទៀត ក្នុងក្របខ័ណ្ឌ សីលធម៌ និងវប្បធម៌ល្អ ។ ប្រជាជនខ្មែរ ប្រមាណ៩៥% ជាពុទ្ធសាសនិកជនទាំងនោះបាន ប្រើប្រព័ន្ធឃោសនាដ៏សំខាន់ ផ្អែកលើមាគ៌ាព្រះពុទ្ធសាសនា ដែលជាមាគ៌ាដ៏ សមស្របមួយសម្រាប់បង្រៀន និងរៀនសូត្រអំពីគោលគំនិត សំខាន់ៗនៃបរិស្ថានដល់ ប្រជាពលរដ្ឋនិងសហគមន៍នានា ដើម្បីឲ្យមានលទ្ធភាពកាន់តែប្រសើរឡើងថែមទៀត ចំពោះការយកចិត្តទុកដាក់ថែទាំបរិស្ថានដែលក្នុងនោះ វត្តអារាមបានក្លាយជានិមិត្តរូបនិង មជ្ឈមណ្ឌលអប់រំដ៏មានប្រសិទ្ធភាព សម្រាប់សហគមន៍មូលដ្ឋាន។ វត្តអារាម បានជួយប្រជាពលរដ្ឋកម្ពុជា ឲ្យធ្វើដំណើរតាមគន្លងទិសដៅមួយនៃការអភិវឌ្ឍន៍ ដើម្បីធានានិរន្តរភាពនិងឈានទៅរកអនាគតមួយ ដែលប្រជាពលរដ្ឋអាចរស់ នៅដោយចុះសម្រុងជាមួយធម្មជាតិ វប្បធម៌និងខ្លួនរបស់គេផ្ទាល់។ ម្យ៉ាងទៀត ទស្សនៈ របស់សាសនាស្តីពីវិបត្តិបរិស្ថាន ក៏បានលើក ទឹកចិត្តដល់ការអភិវឌ្ឍន៍ ទស្សនៈអភិសមាចារបូក្រមសីលធម៌ ទាំងក្នុងពុទ្ធចក្រ ទាំងក្នុងអាណាចក្រនៅក្នុងប្រទេសកម្ពុជាយើងផងដែរ ក្នុងទស្សនៈ សច្ចធម៌របស់ពុទ្ធសាសនាមួយបានបញ្ជាក់ថា ការចាប់កំណើតមិន អាស្រ័យលើខ្លួនឯង ភាសាបាលីថា=បនិច្ចសមុប្បាទ។ ក្នុងព្រះពុទ្ធសាសនា គេស្គាល់ថានេះជាច្បាប់លក្ខខណ្ឌ រាល់សភាវៈ ទាំងអស់នៅក្នុងចក្រវាឡ ដែលតែងតែមានទំនាក់

ទំនងនិងអាស្រ័យ និងគ្នាទៅ វិញទៅមកគ្មានអ្វីអាចរស់បាន មានជីវិតដោយខ្លួនឯងបានឡើយ ។ គោលការណ៍បដិច្ចសមុប្បាទ លើកទឹកចិត្តនៃការគោរពនិងយោគយល់គ្នារវាង មនុស្សជាតិគ្រប់រូបនិងសភាវៈដែលឋិតនៅជុំវិញខ្លួនមនុស្ស គឺជាផ្នែកមួយមិនអាចផ្តាច់ពីបរិស្ថានបាន។ យើងស្ថិតក្នុងប្រពន្ធ័មួយពេញលេញដែលតភ្ជាប់ យើងទាំងអស់គ្នា (មនុស្ស) ជាមួយវប្បធម៌របស់យើងជាមួយពិភពមានជីវិត និងគ្មានជីវិតដ៏ទៃទៀតរបស់ធម្មជាតិ ។




ការអភិរក្សនិងការពារបរិស្ថាន មិនគ្រាន់តែបានទទួលខុសត្រូវពី រដ្ឋាភិបាលតែឯងប៉ុណ្ណោះ ទេ ថែមទាំងមានការចូលរួមពីប្រជាពលរដ្ឋរស់នៅធ្វើការងារតាមសហគមន៍ជនបទ និងទីក្រុងនានាក៏ត្រូវរួមថែរក្សាការពារផងដែរ ។ ក្នុងវត្តអារាម ព្រះសង្ឃខ្មែរស្ថិតនៅក្នុងឋានៈ មួយដែលអាចមានលទ្ធភាពផ្សព្វផ្សាយ ចំណេះដឹងបរិស្ថានក្នុងសហគមន៍។ ព្រះសង្ឃនិងដូនជី តាជី អាចជួយប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ឲ្យមានការលើកស្ទួយ និងយល់ដឹងអំពី បរិស្ថានដើម្បីប្រើឥរិយាបថនិង ធ្វើអំពើនានា ឲ្យបានល្អដែលពាក់ព័ន្ធ និង ការថែរក្សាបរិស្ថាននៅក្នុងសហគមន៍របស់ព្រះសង្ឃផ្ទាល់ឲ្យបានល្អផង ។

វត្តអារាមមានតួនាទី មិនគ្រាន់តែសម្រាប់ប្រារព្ធធ្វើពិធីបុណ្យផ្នែកសាសនា ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបម្រើជីវិភាពផ្នែកសង្គមនិង វប្បធម៌របស់ ស្រុកភូមិថែមទៀត។ តាមប្រពៃណី យូរលង់មកហើយ វត្តជាមជ្ឈមណ្ឌលសិក្សារបស់សហគមន៍មួយយ៉ាងសំខាន់ ទោះបី អាក់ខានរយៈពេលប៉ុន្មានទសវត្ស ថ្មីនេះ ដោយសារតែការរំដើបរំជួលផ្នែកសង្គម និយោបាយ។ សព្វថ្ងៃនេះវត្តកំពុងចាប់ផ្តើមមានមុខមាត់ ជាថ្មីម្តងទៀត ក្នុងការដើរ តួជាមជ្ឈមណ្ឌលរបស់សហគមន៍ ហើយកំពុងតែធ្វើជាគំរូនិងជួយអប់រំគេក្នុងការ ជំរុញ សកម្មភាពខ្លួនជួយខ្លួនឯងដើម្បីកែលម្អគុណភាពនៃជីវិភាពរបស់សហគមន៍។

មនុស្ស សត្វ និងរុក្ខជាតិចូលចិត្តរស់នៅផ្តុំគ្នាក្នុងលោកនេះដែល បណ្តាលឲ្យកើតជាសង្គមឡើង។យើងអាចនិយាយបានថា កើតមកពីអវិជ្ជា និង សង្ខារដែរ ព្រោះអវិជ្ជា និងសង្ខារនេះ ហើយដែលប្រមូលផ្តុំផ្សំធាតុដីទឹក ភ្លើង ខ្យល់ អាកាសឲ្យរួបរួម គ្នាជាពួក ក្រុមជាសង្គម កកើតបន្តៗតាំងពីតិណជាតិ រុក្ខជាតិមកជាសត្វល្អិត ពីសត្វល្អិត មកសត្វធំ ពីសត្វធំមកជាមនុស្ស ។

អាស្រ័យដោយពូជដើមរបស់ពិភពលោក ដែលមាននិស្ស័យបែបនេះទើបវត្ថុធាតុទាំងអស់ក្នុងលោកចម្រើនលូតលាស់បាន។ គឺដោយសារតែសង្គមគឺការផ្តុំផ្សំសាមគ្គីរួបរួមគ្នាទើបចាំបាច់ត្រូវពឹងពាក់គ្នាដើម្បីរស់រៀងខ្លួន។ ដូច្នេះវត្តអារាមបានបណ្តុះទំនាក់ទំនងរវាងមនុស្ស សត្វ និងធម្មជាតិដោយពឹងផ្អែកលើការអាស្រ័យគ្នាទៅវិញទៅមកហើយមិនត្រូវទាញយកប្រយោជន៍ហួសហេតុពីធម្មជាតិ។ កុំនិយាយឡើយដល់ទៅវត្ថុមានចិត្តវិញ្ញាណ ដូចមនុស្ស សត្វ ជាដើម សូម្បីវត្ថុគ្មានចិត្តវិញ្ញាណដូចជា តិណជាតិ រុក្ខជាតិជាដើមនេះក៏ត្រូវការសង្គមជាចាំបាច់ដើម្បីជីវិត

ខ្លួនដែរ។ ការបាត់បង់សង្គមណាមួយក្នុងចំណោមសង្គមណាមួយ មានសង្គមរុក្ខជាតិជាដើម ពុំគ្រាន់តែធ្វើអោយប៉ះពាល់ដល់បរិស្ថានទេ ដូចជាការបង្កើតអោយមានគ្រោះរាំងស្ងួត និងទឹកជំនន់ ប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងសត្វព្រៃក៏បាត់បង់ដែរ ព្រោះថាធ្វើអោយសត្វគ្មានជំរកតាមរយៈការបរបាញ់ផ្សេងៗ។ លោក កូហ្វីអាណាន់ អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិមានប្រសាសន៍ថា «ការប្រែប្រួលអាកាសធាតុកំពុងតែធ្វើអោយវិបត្តិម្ហូបអាហារពិភពលោកកាន់តែធ្ងន់ធ្ងរទៅៗ ហើយបណ្ដាប្រទេសក្រីក្រជាច្រើនអាចប្រឈមមុខនិងការចាប់ផ្ដើមនៃគ្រោះមហន្តរាយ ភាពអត់ឃ្លានដ៏ធំមួយ ការប្រែប្រួលអាកាសធាតុទាំងនេះគឺជាការគំរាមកំហែងដល់សុខភាពមនុស្ស សន្តិសុខ ស្ថានភាពនយោបាយ និងសង្គមកិច្ចការប្រែប្រួលអាកាសធាតុ នាំអោយមានគ្រោះមហន្តរាយផ្សេងៗ ដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ រលកកម្ដៅនិងការកើនឡើងនៃកម្ពស់ទឹកសមុទ្រ។ ធនធានធម្មជាតិគឺជាប្រភពធនធានមួយដ៏រស់រវើកនិងមិនចេះរីងស្ងួត ប្រសិនបើយើងទាំងអស់គ្នាចេះគ្រប់គ្រងការពារអភិរក្ស និងប្រើប្រាស់វាអោយបានសមស្របទៅតាមលក្ខណៈបច្ចេកទេស។

ដូច្នេះពួកមនុស្សដែលកើតមាននៅក្នុងសង្គម តែងតែមានតម្រូវការសង្គមជាចាំបាច់ ម្ល៉ោះហើយមនុស្សត្រូវមានចិត្តគំនិត ចរិយាមាយាទជាអ្នកស្រលាញ់សង្គមជួយលើកកម្ពស់សង្គមជាចាំបាច់ថែមទៀត បាននិយថា មនុស្សត្រូវជួយសង្គមផងទើបសង្គមជួយយើងបាន។ គោលដៅយូរអង្វែងរបស់ប្រទេសកម្ពុជាគឺ ការអភិវឌ្ឍន៍ និងការគ្រប់គ្រងធនធានធម្មជាតិ ជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ប្រកបដោយនិរន្តរភាពដែលការងារ

ទាំងនេះ ជាការចូលរួមចំណែកដើម្បីជាការកាត់បន្ថយ ភាពក្រីក្រ របស់ប្រជាជនយើងនិងការអភិវឌ្ឍន៍ សេដ្ឋកិច្ចសង្គមអោយកាន់តែប្រសើរ។[1]

**អារាមមានន័យថា:** ប្រទេស ឬ ទីដែលនាំទឹកចិត្តឲ្យរីករាយសប្បាយ គឺសួន សួនច្បារ អាវាសដែលមានសួនច្បារនិងកុដិលំនៅនៃពួកបព្វជិត។ល។ ខ្មែរហៅចំពោះតែទីវត្តរបស់បព្វជិតថាអារាម ឬវត្តអារាម (ទីវត្តបានជាគេហៅអារាមព្រោះកាលពីក្នុងសម័យបុរាណព្រេងនាយគេច្រើនយកសួនច្បារ និង ឧទ្យានធ្វើជាទីអាវាសសម្រាប់ពួកបព្វជិតដូចយ៉ាងវត្តវេឡុវន) ក្នុងពុទ្ធកាលជាដើម ។

វត្តអារាមបានចូលរួមយ៉ាងសកម្មក្នុងការងារថែរក្សាបរិស្ថាននៅជុំវិញវត្ត ភូមិ ឃុំ ស្រុក ខេត្ត និងប្រទេសទាំងមូលដូចជា ការបណ្តុះ ការដាំ និង ការពារព្រៃដោយៈ

ដោយការដាំក្នុងវត្តអារាម ក្នុងនោះព្រះសង្ឃចូលរួមអប់រំណែនាំពុទ្ធបរិស័ទឲ្យយល់ដឹងអំពីខ្លឹមសារបរិស្ថាន និង ការការពារព្រៃឈើទាំងឈើស៊ីផ្លែនិងឈើប្រើប្រាស់ណែនាំការដាំការការពារការថែរក្សាបរិស្ថានឲ្យមានបានលទ្ធផលល្អ ត្រូវឲ្យចេះទាំងខាងក្នុងផងនិងខាងក្រៅផង ពិសេសព្រៃឈើដែលមានមកហើយ ក៏មិនត្រូវកាប់បំផ្លាញទាំងក្នុងនិងព្រៃក្រៅទាំងឡាយនោះ។ ការការពារព្រៃឈើនិងដាំដើមឈើបន្ថែមណែនាំបរិស័ទក្នុង ភូមិ ឃុំ ឲ្យយល់ដឹងពីសារៈប្រយោជន៍បរិស្ថាននិងឲ្យអ្នកស្រុកដាំដើមឈើឲ្យ បានច្រើនតាមរយៈព្រះសង្ឃដែលសម្តែងធម៌ទេសនា។ ហើយព្រះសង្ឃដែលជាអ្នកគង់នៅក្នុងវត្តអារាមនីមួយៗត្រូវដាំឈើធ្វើជាគំរូមុនបរិស័ទក្នុងការការពារ និង ការដាំដើមឈើ។

[1] ទំព័រទី២ ដល់ទី១១ ដកស្រង់ពីសៀវភៅ ពុទ្ធសាសនា និងការអភិវឌ្ឍន៍សង្គមខ្មែរ ទំព័រ៧៣និង១៥០

ថែមទាំងត្រូវចូលរួមហាមឃាត់ការកាប់ឈើ បង្កើតកម្មវិធីរុក្ខវប្បកម្មក្នុងវត្តអារាម ដោយភ្ជាប់ទៅនឹងការពន្យល់ណែនាំពុទ្ធបរិស័ទពីវិធីសាស្ត្រក្នុងការដាំដើមឈើ។ ហើយបន្ទាប់ពីការពន្យល់ណែនាំបរិស័ទព្រះសង្ឃដែលគង់នៅវត្តអារាមត្រូវតាមដានពីលទ្ធផលនៃការផ្សព្វផ្សាយព្រមទាំងភ្ជាប់នូវរាល់លទ្ធផលរួចធ្វើរបាយការណ៍ទុកជាឯកសារ។

ម៉្យាងទៀតវត្តអារាម ដែលមានព្រះសង្ឃជាអ្នកដើរ តួនាទីក្នុងទាមទារឲ្យអនុវត្តច្បាស់ជាទូទៅក្នុងការពារបរិស្ថាន ដោយការពារព្រៃឈើ ព្រមទាំងជម្រុញពុទ្ធបរិស័ទដែលនៅជុំវិញវត្តអារាមឲ្យបណ្ដុះពូជកូនឈើគ្រប់ប្រភេទរួចសហការជាមួយសិស្សានុសិស្ស ដើម្បីយកទៅដាំដុះលើផ្ទៃដី ដែលអាចដាំបាន ក្នុងគោលបំណងលើកស្ទួយការទប់ស្កាត់នូវរាល់គ្រោះធម្មជាតិ ទាំងនេះជាអ្វីដែលវត្តអារាមបាននឹងកំពុងអនុវត្តតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន ដែលនៅតែមានការចូលរួមយ៉ាងសកម្មចំពោះបញ្ហាបរិស្ថាន ។

## ព្រះសង្ឃនិងការតិវឌ្ឍន៍សង្គមបរិស្ថាន

ប្រជាពលរដ្ឋខ្មែរជាអ្នកគោរពរាប់អានព្រះពុទ្ធសាសនាតាំងពីបុរាណកាលមករហូតបច្ចុប្បន្នកាលនេះ ។ ពុទ្ធបរិស័ទបច្ចុប្បន្នទាំង៤ជាពួកគឺ ភិក្ខុ , សាមណេរ , ឧបាសក និង ឧបាសិកា ។ បណ្ដាពុទ្ធបរិស័ទទាំង៤ពួកនេះ និយាយឲ្យខ្លីមកនៅត្រឹម២ពួកគឺ គ្រហស្ថ គឺអ្នកមិនបួស១ និង បព្វជិត គឺអ្នកបួស១ ។ បព្វជិត ឬ អ្នកបួស បានដល់ព្រះសង្ឃនេះឯងដែលជាបុគ្គលគោរពប្រតិបត្តិព្រះពុទ្ធសាសនាបានប្រសើរ និងថ្លៃថ្លាជាងគ្រហស្ថ ហើយជាស្រែបុណ្យសម្រាប់មនុស្សលោកទូទៅ ។

ព្រះសង្ឃនៅរក្សាសំខាន់ក្នុងសង្គម តាំងពីបុរាណកាលមក ព្រះអង្គមាន កិត្យានុភាពខ្ពស់ ហើយមានឥទ្ធិពលធំធេងណាស់ទៅលើជីវភាពរបស់ប្រជាជន។ ព្រះសង្ឃបានលះបង់អ្វីៗគ្រប់បែបយ៉ាង ព្រះអង្គបានចូលរួមយ៉ាងសកម្មក្នុងការកសាងវត្តអារាម ធ្វើឲ្យទីវត្តក្លាយទៅជារមណីយដ្ឋាន ជាទីសក្ការបូជា។ ព្រះអង្គចូលរួមក្នុងកិច្ចអភិវឌ្ឍន៍សង្គមជាតិ ព្រះអង្គបានជួយឧបត្ថម្ភ ក្នុងវិស័យសង្គមកិច្ច សិក្សាធិការ សុខាភិបាល និងថែរក្សាបរិស្ថាន។

ការប្រមាថមើលងាយចំពោះរតនៈវត្ថុដ៏ប្រសើរបំផុតនេះ បញ្ជាក់ឲ្យឃើញថា ជាបុគ្គលពាល ល្ងង់ខ្លៅ ជាអ្នកបំផ្លាញគុណធម៌ សីលធម៌ និងសន្តិភាព ជាមនុស្សវិនាស មិនស្គាល់បាបបុណ្យ គុណ ទោស ខុស ត្រូវ អ្វីទាំងអស់ ឡើតព្រះសង្ឃជាអ្នករក្សាសីល ។ ហេតុនេះ បុគ្គលទាំងឡាយណាមិនគោរពគុណព្រះសង្ឃ(ព្រះសង្ឃដែលគោរពប្រតិបត្តិសិក្ខាបទបានល្អ ) ជាបុគ្គលទ្រុស្តសីល ហើយបុគ្គលទ្រុស្តសីលរមែងមិនសង្គ្រោះនូវភាពសាន្តត្រាណរបស់បុគ្គល និង សង្គមឡើយ ហើយក៏រមែងបង្កឲ្យមានភាពច្របូកច្របល់សោកសៅក្តៅក្រហាយដល់បុគ្គលនិងសង្គម។ តាមពិតព្រះសង្ឃដែលសិក្សារៀនសូត្រ និងគោរពប្រតិបត្តិតាមធម៌វិន័យដ៏ល្អនេះ គឺជាធនធានមនុស្សដ៏ប្រកបទៅដោយគតិបណ្ឌិតខ្ពង់ខ្ពស់ គួរជាទីគោរពបំផុត ហើយជាប្រភពនៃគុណធម៌ សីលធម៌ និងសន្តិភាព ដែលមនុស្ស-សត្វគ្រប់រូបក្នុងលោកតែងតែចង់បានដូចៗគ្នាមិនថាអតីតកាល បច្ចុប្បន្នកាលឬទៅពួងអនាគតកាលឡើយ។

បើមានព្រះសង្ឃ (មិនមែនបុគ្គលសង្ឃទ្រុស្តសីល ) ត្រូវតែមានសីល បើមានសីលពិតហើយ ទើបពិភពលោកបានសុខក្សេមក្សាន្ត ព្រោះមនុស្សមិនបៀតបៀនកាប់សម្លាប់គ្នា មិនលួច ប្លន់ កេងប្រវ័ញ្ច ពុករលួយ មិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺលុបបំបាត់ការជួញដូរមនុស្ស ជួញដូរផ្លូវ

ភេទ និងជំងឺកាមរោគទាំងឡាយ មានជំងឺអេដស៍ជាអាទិ៍ មិនកុហក កុត ករ ឆបោក នាំឲ្យមនុស្សមានភាពជឿជាក់ មានក្តីសង្ឃឹម និងមានទំនុក ចិត្តគ្នា មិនសេព ផឹក ហិត ជក់គ្រឿងញៀនគ្រប់ប្រភេទ លុបបំបាត់ការ ជួញដូរគ្រឿងញៀន។

ព្រះសង្ឃគឺជាអ្នកសិក្សារៀនសូត្រ និងអប់រំផ្លូវចិត្តឲ្យបានល្អបរិសុទ្ធ មិន ត្រឹមតែការសិក្សាព្រះពុទ្ធសាសនា និងប្រពៃណី ទំនៀមទម្លាប់ប៉ុណ្ណោះ ទេ វិជ្ជាជីវៈផ្សេងៗដូចជាជាងឈើ ជាងដែក ជាងគំនូរ ជាងចម្លាក់ ផ្សំថ្នាំ ព្យាបាលជំងឺ ជួយបង្ហាត់បង្រៀន កូនខ្មែរឲ្យចេះអក្សរសាស្ត្រ លេខនព្វន្ត អក្សរសិល្ប៍ វប្បធម៌ វិជ្ជាជីវៈ និងសង្គមកិច្ចផង ។ ព្រះសង្ឃជាអ្នកជួយដោះ ស្រាយបញ្ហារបស់ពុទ្ធបរិស័ទពេលមានវិបត្តិផ្លូវចិត្ត ព្រះសង្ឃនើរតួជា មេធាវីដោះស្រាយទំនាស់ សម្រុះសម្រួលឲ្យអ្នកដទៃបាន បានផ្សះផ្សា និង សន្តិភាព ។

ព្រះសង្ឃ ជាទីទុកចិត្តនៃពុទ្ធបរិស័ទ ជាជំហរក្នុងការកសាងសមិទ្ធផល នានា ដូចជា ជីកអណ្តូង ជីកស្រះ លើកថ្នល់ សាងស្ពាន សាងសាលារៀន មន្ទីរពេទ្យ ។ ល ។ ពេលខ្លះទៀតព្រះសង្ឃជាអ្នកព្យាបាលជំងឺដល់ប្រជា ពលរដ្ឋ ដោយផ្សំឱសថបុរាណ ជាមួយនឹងពុទ្ធមន្ត ដើម្បីជួយលើកកម្លាំង ចិត្ត ដែលជាប្រភពនៃថាមពល ។ ពេលខ្លះទៀត ជាចិត្តវិទូ ពន្យល់ពុទ្ធ បរិស័ទដែលមានវិបត្តិផ្លូវចិត្ត ឬ ខូចចិត្តឲ្យបានជាសះស្បើយ ដោយព្រះ ធម៌ ឬ ឲ្យធ្វើសម្មាធិកម្មដ្ឋាន ។ ពេលខ្លះទៀតព្រះសង្ឃមានសមត្ថភាព ជួយឃោសនាប្រមូលថវិកា ឬ សម្ភារៈ ពីញាតិញោម និង សប្បុរសជនពី គ្រប់មណ្ឌលដ្ឋានទៅ ជួយសង្គ្រោះប្រជាពលរដ្ឋ ដែលមានជំងឺឲ្យបានចូល ទៅសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ឬ រងគ្រោះដោយធម្មជាតិ មានខ្យល់ ព្យុះ ទឹកជំនន់ ភ្លើងឆេះផ្ទះ ។ ល ។ លើសពីនេះទៅទៀត ព្រះសង្ឃ ជួយ ចិញ្ចឹមជនអនាថា មានមនុស្សចាស់ជរាគតទីពឹង ស្ត្រីមេម៉ាយ កុមារកំព្រា

សិស្សានុសិស្ស ដោយផ្តល់ទីវត្តអារាមឲ្យស្នាក់អាស្រ័យដើម្បីសិក្សារៀនសូត្រ។

សរុបសេចក្តីមក ព្រះសង្ឃខ្មែរបានជួយកសាងសង្គម ដោយបង្កើតឡើងនូវសមិទ្ធផលយ៉ាងច្រើនសន្ធឹកសន្ធាប់ សូមឲ្យប្រជាពលរដ្ឋខ្មែរ គ្រប់មជ្ឈដ្ឋានមេត្តាយល់ត្រូវឲ្យបានគ្រប់គ្នាឡើង ហើយមានសទ្ធាជ្រះថ្លាសិក្សារៀនសូត្រទ្រឹស្តីព្រះពុទ្ធសាសនាផ្សារភ្ជាប់ជាមួយនិងការថែរក្សាបរិស្ថានធម្មជាតិ។

- **បរិស្ថានជាអ្វី?**

បរិស្ថានគឺជាវិទ្យាសាស្ត្រឬ ជាការសិក្សាអំពីបរិស្ថាន គឺជាមុខវិជ្ជាមួយដែល សិក្សាអំពីអ្វី ដែលនៅជុំវិញយើង និងគឺជាការសិក្សាអំពីទំនាក់ទំនងនែ សកម្មភាពមនុស្ស ដែលមាន ឥទ្ធិពលទៅលើបរិស្ថាន និងដែលជាវត្ថុមានជីវិត និងគ្មានជីវិត ប៉ុន្តែអ្វីទៅ ដែលជា និយម ន័យពិតប្រាកដរបស់បរិស្ថាន ? លោកCunningham បានធ្វើការកត់សម្គាល់លើពាក្យ បរិស្ថានថា(វាមកពីពាក្យភាសាបារាំង Environner វាមានន័យថាជាការព័ទ្ធជុំវិញ ឬរបស់នៅជុំវិញ) គឺជាលក្ខខ័ណ្ឌៈ ទាក់ទិនគ្នានៅក្នុងសង្គម និងវប្បធម៌ឥទ្ធិពលលើបុគ្គល ណាមួយ ឬ សហគមន៏រស់នៅ។ ខណៈដែលមនុស្សបានរស់នៅលើពិភពលោកយើង ព្រមទាំងបានបង្កើតលើនៅខាងបច្ចេកវិទ្យា សង្គម និងវប្បធម៌នានា លើពិភពលោក ទាំងនេះជាផ្នែកមួយនៃបរិស្ថានផងដែរ ។

ពាក្យថាបរិស្ថានយើងអាចឲ្យនិយមន័យផងដែរថាៈ ទីមួយគឺជា ដីសមុទ្រ ខ្យល់ អាកាសធាតុ រុក្ខជាតិ និងអ្វីៗដែលនៅជុំវិញយើងដែលមានមនុស្ស សត្វ និងរុក្ខជាតិផងដែរ ទាំងនេះហៅថា បរិស្ថានរូប ។ទីពីរ គឺក

ត្តាទាំងឡាយណាដែលមានហេតុប៉ះពាល់ លើប្រភេទសារពាង្គកាយណាមួយ ឬ ក៏ជះឥទ្ធិពលលើពិភពលោកយើងទាំងមូល ។បរិស្ថានរបស់យើងគឺជាវត្ថុទាំងឡាយដែលនៅជុំវិញយើង ហើយវាមានឥទ្ធិពលដល់យើង វិញដោយរួមមានទាំងអ្វីដែលបានមកពីធម្មជាតិ ឧទាហរណ៍ ដើមឈើ មច្ឆាជាតិ ទឹកភ្លៀង គឺបរិស្ថានធម្មជាតិ។ អ្វីៗដែលបង្កើតដោយស្នាដៃមនុស្ស ឧទាហរណ៍មាន ទូរស្សន៍ និងរថយន្ត គឺបរិស្ថានបង្កើតដោយមនុស្ស។ ចំណេះដឹង និង ជំនឿ ផ្សេងៗ របស់ សហគមន៍ រស់នៅគឺបរិស្ថានវប្បធម៌ ។ មាគ៌ាដឹកនាំផ្សេងៗ ហើយនិងក្រុមទាំងឡាយ ដែលបានរៀបចំឡើង គឺជាបរិស្ថានសង្គម ។ ទ្រព្យសម្បត្តិដែលយើងមាន ឬក៏មិនមាន ហៅថា បរិស្ថានសេដ្ឋកិច្ច ហើយនិងអ្វីដែលបានអនុវត្ត លើសីលធម៌ ដែលវាពិនិត្យលើសុជីធម៌លើការទទួលខុសត្រូវ ក្នុងការរស់នៅ គឺជាក្រុម បរិស្ថានក្នុងការរស់នៅ ។

បរិស្ថានទាំងនេះ គឺត្រូវតែមានការពឹងអាស្រ័យគ្នាទៅវិញទៅមក ។បរិស្ថានធម្មជាតិបាន ផ្តល់នៅអ្វីដែលយើង ត្រូវការអាស្រ័យរស់នៅ ឧទាហរណ៍ ដូចជា ខ្យល់ ទឹក ហើយនិង សត្វ រុក្ខជាតិគ្រាប់ ប្រភេទដែលយើងត្រូវការប្រើប្រាស់វា ។ វាបានផ្តល់ផងដែរ នៅសំភារៈ

ប្រើផ្សេងៗ (ដូចជាឈើ ប្រេង កាត ថ្ម និងដែក ) ដែលយើងប្រើវា ដើម្បីបង្កើត បរិស្ថានដែលបានកសាងដោយមនុស្ស ហើយនិងដើម្បីផ្លាស់ប្តូរបរិស្ថានសេដ្ឋកិច្ច។ បរិស្ថានសង្គម វប្បធម៌ ជួយយើងឲ្យយល់ដឹងអំពីការរស់នៅរបស់ និងវាមានការទាក់ទងគ្នា ជាមួយនិងបរិស្ថានធម្មជាតិ ។ តាមការលើកឡើងនៅអត្ថន័យ ដែលទាក់ទងទៅ បរិស្ថានខាងលើ យើងផ្តល់ជានិយមន័យរួម គឺអ្វីៗទាំងអស់ដែលមានជីវិត ឬគ្មានដែលនៅជុំវិញខ្លួនយើង ដោយរាប់បញ្ចូលទាំងសកម្មភាព របស់មនុស្សផងដែរ

ពាក្យថាបរិស្ថាន ដើម្បីឲ្យវាសមស្របតាមការសិក្សាបរិស្ថានយើងអាចបែងចែកនិយមន័យ បរិស្ថានជាពីរផ្នែកធំៗ ទីមួយ គឺបរិស្ថានធម្មជាតិ ទីពីរ បរិស្ថានសង្គមវប្បធម៌ ។

- **បរិស្ថានធម្មជាតិ:** ធម្មជាតិមានន័យថាមិនបានបង្កើតឡើងដោយមនុស្សនោះឡើយ។ ឧទាហរណ៍ បរិស្ថានគ្មានជីវិត គឺស្ទឹង ទន្លេ បឹង សមុទ្រ ហាមសមុទ្រ ភ្នំនិងកត្តាអាកាសធាតុ រួមបញ្ចូលទាំងសីតុណ្ហភាព សំណើម ភ្លៀង ការធ្លាក់ព្រិល ខ្យល់។ ពពួកសត្វ សត្វស្លាប រុក្ខជាតិ ដើមឈើជាផ្នែកនៃបរិស្ថានមានជីវិត ។កត្តាដែលជះ ឥទ្ធិពល លើបរិស្ថានធម្មជាតិ គឺមានពីរធំៗ មួយកត្តារូប ឬ អាប្ប៊ូទិក (គ្មានជីវិត) ពីរ (កត្តាជីវៈសាស្ត្រ) ឬ ប៊ូទិក (មានជីវិត) បរិស្ថានទាំងនេះគឺបង្ហាញ ពីទិដ្ឋភាពទូទៅនៃបរិស្ថានទាំងមូល។
- **បរិស្ថានសង្គម-វប្បធម៌** ឬក៏ (បរិស្ថានបង្កើតដោយមនុស្ស) គឺអ្វីៗដែល មាន នៅជុំវិញយើង គឺបរិស្ថានទាំងនេះត្រូវបានបង្កើតដោយមនុស្ស និងចំណេះដឹងដែលរួមមាន ស្ថាប័នសង្គមផងដែរ ។វាត្រូវចែកជាពីរផ្នែក ផ្នែកគ្មានជីវិត និងមានជីវិត ។ ផ្នែកគ្មានជីវិតនៃបរិស្ថានសង្គម វប្បធម៌រួមមានទាំងសំណង់ ផ្លូវថ្នល់ ស្ពាន់ទីក្រុង ភូមិស្ថាន ធារាសាស្ត្រ ប្រឡាយទឹក រោងចក្រ ។ បរិស្ថាននេះគឺត្រូវបានបង្កើត ដោយស្នាដៃមនុស្ស ដែលហៅថា បរិស្ថានបង្កើត ដោយមនុស្សឬបរិស្ថានសំណង់ ។ផ្នែកមានជីវិត នៃបរិស្ថាន សង្គមវប្បធម៌គឺរួមមានសង្គម សាំញ៉ាំ និងសកម្មភាព សង្គម រស់នៅដែលកើតឡើង ពីរ វប្បធម៌រួមមានទាំងទំរង់ ផ្សេងៗគ្នា នៃលក្ខណៈសង្គម ដូចជាសិល្បៈអក្សរសាស្ត្រ សិលាវិក ។ទិដ្ឋភាពទាំងឡាយនៃវប្បធម៌ គឺជាផ្នែក មួយ នៃបរិស្ថាន ដែល បង្កើត ដោយមនុស្ស ។

វត្តអារាម និងការងារ អភិវឌ្ឍន៍សហគមន៍ តាមរយៈវត្តអារាមព្រះពុទ្ធសាសនាតែងតែតាំងទីស្ថិតនៅក្នុងឬក្បែរភូមិហើយមានតួ

នាទីអប់រំបរិស័ទឲ្យថែរក្សាបរិស្ថាន។ បច្ចុប្បន្ន វត្តអារាមកំពុងចាប់ផ្តើម ដើរតួនាទីធ្វើជាគម្រូ និងអប់រំមហាជនគ្រប់ស្រទាប់ ក្នុងការជម្រុញសកម្មភាពខ្លួនឯង ជួយខ្លួនឯង ដើម្បីកែលម្អគុណភាពនៃជីវិតរបស់សហគមន៍។ ប្រទេសកម្ពុជាមានប្រពៃណី ដ៏យូរលង់ណាស់មកហើយ វត្តអារាមជាមជ្ឈមណ្ឌលសិក្សារបស់ សហគមន៍មួយយ៉ាង សំខាន់ មានអង្គភាពនៅជនបទមួយចំនួនដូចជា គណៈទានជន អង្គការសហគមន៍ ព្រមទាំងសកម្មភាពអភិវឌ្ឍន៍ សហគមន៍មាន ផ្លូវថ្នល់ សាលារៀន ទាំងអស់នេះមួយចំនួន ដឹកនាំដោយព្រះសង្ឃ ។

ព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ ទ្រង់ប្រកាន់ថា ធម្មជាតិមានគុណភាពខាងសោភ័ណ្ឌភាព និងភាពស្ងប់ស្ងៀបបរិសុទ្ធ ដែលអាចបណ្តុះចិត្តគំនិត និងដឹកនាំទៅដល់ការធ្វើ សមាធិភាវនា បាន។ ព្រះបរមគ្រូជាអង្គម្ចាស់ ទ្រង់បានលើកទឹកចិត្ត ដល់អ្នកមានសទ្ធាជ្រះថ្លារបស់ព្រះអង្គ ឲ្យចេះខាងសង់វត្តអារាមនានា។ វត្តអារាមនៅប្រទេសកម្ពុជាយើង ច្រើនតែសាងសង់ ឡើងនៅតាមបណ្តោយមាត់ទឹក ស្ទឹងដែលបានហ៊ុំព័ទ្ធដោយព្រៃព្រឹក្សាលតាវល្លិ៍ ឬទីតាំងនៅលើកំពូលភ្នំ ដែលជាទីកន្លែងដែលមានខ្យល់ អាកាសបរិសុទ្ធនៃបរិស្ថានស្អាត ធ្វើឲ្យប្រសើរនិងមានអារម្មណ៍ស្រស់ស្រាយខាងផ្លូវចិត្ត។ អាគារនៃព្រះវិហារនិមួយៗជាធម្មតាហ៊ុំព័ទ្ធទៅដោយរុក្ខជាតិ បុប្ផា ស្រះទឹក ព្រមទាំងដើមឈើ ដើម្បីបង្កើតឲ្យមានឧទ្យានសន្តិភាព សម្រាប់ធ្វើសមាធិផងដែរ។

## ॥ សេចក្ដីសន្និដ្ឋាន

តាមការសិក្សាស្រាវជ្រាវមកឃើញថា វត្តអារាម មានការទំនាក់ទំនងគ្នាយ៉ាងជិតស្និត ជាមួយបរិស្ថានធម្មជាតិ និងការជួយដល់សង្គមខ្មែរជាច្រើន ជួយដល់ការងារ អភិវឌ្ឍន៍ថែរក្សាការពារធនធានធម្មជាតិ ដូចជាការពារព្រៃឈើ ដាំកូនឈើជាដើម វត្តអារាម គឺជាទីសការៈបូជារបស់ពុទ្ធសាសនិក វត្តដើរតួនាទីយ៉ាងសំខាន់ ដល់ការអប់រំដល់បរិស័ទឲ្យចេះស្រលាញ់បរិស្ថាន ដូចជាជីវិតខ្លួនឯងថឹង វត្តជាទីជួបជុំគ្នារបស់បរិស័ទក្នុងការធ្វើសេចក្ដីល្អ ដើម្បីស្វែងរកសេចក្ដីសុខ មួយវិញទៀតវត្តអារាមក៏ជាកន្លែងស្ងប់ស្ងាត់ សម្រាប់ប្រជាជនគ្រប់រូប ។ ហើយមនុស្សគ្រប់រូបរស់នៅជាមួយបរិស្ថានដែលធ្វើឲ្យជីវិតយើងសមស្របសម្រប់សម្រួលជាមួយធម្មជាតិ ។

ហើយមួយវិញទៀត វត្តអារាម ក៏ជាតំណាងអោយសភាវៈល្អផងដែរ។ បានជាប្រជាពលរដ្ឋខ្មែរ តែងប្រារព្ធធ្វើបុណ្យតាមប្រពៃណី ជួបជុំពុទ្ធបរិស័ទប្រកបដោយមិត្តភាព សាមគ្គីភាព ភាតរភាព សោមនស្សរីករាយ និងមានសេចក្ដីសង្ឃឹមក្នុងជីវិតរស់នៅ។ ហើយវត្តអារាម មានទំនាក់យ៉ាងជិតស្និតជាមួយការជួយសង្គមគ្រួសារ ក៏ដូចជាសង្គមជាតិ ដោយផ្ដល់នូវការអប់រំ ដំបូន្មានប្រកបដោយធម៌ឲ្យបានសេចក្ដីសុខសន្តិភាព ក្នុងការរស់នៅក្នុងសង្គមគ្រួសារ និងសង្គមជាតិផងដែរ។

តាមរយៈវត្តអារាម បានធ្វើឲ្យសង្គមខ្មែរមានឧត្តមគតិស្នេហាជាតិមាតុភូមិ ស្រឡាញ់ជឿនវប្បធម៌ជាតិ និងអរិយធម៌ជាតិ។ ការយល់ដឹងពីអំពើល្អ បានធ្វើឲ្យសមាជិកគ្រួសារក្នុងសង្គមខ្មែរ ប្រកាន់យកជានិច្ចនូវសីលធម៌ល្អ ធ្វើអ្វីៗដោយអំណត់ព្យាយាម សុចរិតទៀងត្រង់ សុភាពរាបសារ មានសាមគ្គីធម៌ និងដឹងសុខទុក្ខគ្នា ព្រមទាំងចេះជួយឧបត្ថម្ភគ្នាទៀតផង។

វត្តអារាម ជាប្រភពផ្ដល់ចំណេះដឹងខាងផ្លូវធម៌ និងផ្លូវសេវាកម្មសង្គម បានសេចក្ដីថា រាល់បញ្ហាក្នុងសហគមន៍ គឺមានព្រះសង្ឃ តាអាចារ្យ ឧបាសក ឧបាសិកា ចូលរួមដោះស្រាយដែរ។

វត្តអារាម មានតួនាទីសំខាន់ណាស់ក្នុងកិច្ចអភិវឌ្ឍន៍សង្គមជាតិ ដូចជាការចលនាតាមគ្រប់រូបភាពដូចជា: ការកសាងវត្តអារាម សាង សង់សាលារៀនក្នុងវត្ត ធ្វើមន្ទីពេទ្យ ស្ពាន ថ្នល់ សួនច្បារ ជីកស្រះទឹក ដាំដើមឈើ ថែរក្សាការពារបរិស្ថាន។ ម្យ៉ាងទៀត វត្តអារាម ក៏រួមចំណែកដោះស្រាយការងារសង្គមនៃរដូចជា ការទទួលខ្ទបត្ថម្ភកន្លែងស្នាក់អាស្រ័យ រៀនសូត្រដល់សិស្សនិស្សិតក្រីក្រដែលមកពីជនបទឆ្ងាយៗ និងកុមារកំព្រា កុមារ ជាកូនគ្រួសារក្រីក្រ ព្រមទាំងការជួយខ្ទបត្ថម្ភគាំទ្រដល់ជនចាស់ទីយជាច្រើនទៀតបានស្នាក់នៅសិក្សារៀនសូត្រធម៌អាថ៌ផ្សេងៗ ដែលអាចធ្វើឲ្យជនទាំងនោះ មានសេចក្តីសង្ឃឹមក្នុងជីវិតរស់នៅ។ ទាំងនេះបញ្ជាក់ថា វត្តអារាម មានសារសំខាន់ណាស់ក្នុងការជួយដល់សង្គមជាច្រើន ទាំងការជួយថែរក្សាការពារបរិស្ថានធម្មជាតិ ដែលធ្វើឲ្យការរស់ប្រកបដោយសុខសន្តិភាព និងសុខមាលភាពល្អ ត្រឹមត្រូវ។

# ឯកសារយោង

-១ សៀវភៅ ពុទ្ធសាសនា និងការអភិវឌ្ឍន៍សង្គមខ្មែរ)

-២ ឥទ្ធិពលវត្តអារាមព្រះពុទ្ធសាសនា ក្នុងសង្គមខ្មែរនាសម័យទំនើប(ពសស) សារណាបញ្ចប់បរិញ្ញាបត្រ ជំនាន់ទី៣។

-៣ មូលដ្ឋានគ្រឹះនៃបរិស្ថាន(ឯកសារមេរៀន)(២០០៦ ទំព័ទរ២ ជំពូក១) (របស់លោក ស្ពាន់ រិន)។

៤ សៀវភៅ មេរៀនលោកគ្រូ(បុល មុនី)ពុទ្ធសាសនា និងបរិស្ថាន(មេរៀនទី៣)

-៥ ស្រាវជ្រាវឯកសារតាម Internet ក្នុងគេហទំព័រ 5000years(www.5000-years.org) ជាគេហទំព័រពុទ្ធសាសនាដ៏ធំមួយ គ្រប់គ្រង់ដោយ ឧបាសិក ស្រង់ ចាន់ណា។

៦-វចនានុក្រមសសម្តេច ជួន ណាត